00610529

F6/1

**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០១/១៨-០៧-២០០៧-អវតក/អជតក |
| **ដាក់ទៅ** | : | អង្គជំនុំជម្រះតុលាការកំពូល |
| **ថ្ងៃដាក់** | : | ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញា |
| **ភាសាដើម** | : | **អង់គ្លេស** |

ឯកសារបានទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 28 / 09 / 2010
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ:

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច សុំបន្ថែមពេលវេលាដាក់សារណាបណ្ដឹងសាទុក្ខរបស់ខ្លួន**

---

**អ្នកដាក់ឯកសារ:**
**សហព្រះរាជអាជ្ញា:**
លោកស្រី ជា លាង
លោក Andrew CAYLEY
លោក យ៉េត ចរិយា
លោក William SMITH
លោក សេង ប៊ុនឃាង
លោក Anees AHMED

**អ្នកទទួលឯកសារ:**
**អង្គជំនុំជម្រះតុលាការកំពូល:**
ចៅក្រម គង់ ស្រ៊ីម, ប្រធាន
ចៅក្រម Motoo NOGUCHI
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម A. KLONOWIECKA-MILART
ចៅក្រម ស៊ិន រិទ្ធ
ចៅក្រម C. N. JAYASINGHE
ចៅក្រម យ៉ា ណារិន

**មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី:**
លោក គង់ ពិសី
លោក ហុង គឹមសួន
លោក យុង ផានិត
លោក គីម ម៉េងឃី
កញ្ញា ម៉ូច សុវណ្ណារី
កញ្ញា SILKE Studzinsky
លោកស្រី Martine JACQUIN
លោក Philippe CANONNE
លោកស្រី ទី ស្រ៊ីនណា
លោក Pierre-Olivier SUR

| | |
|---|---|
| **ជនជាប់ចោទ/ដើមបណ្ដឹងសាទុក្ខ:** | លោក Alain WERNER |
| កាំង ហ្គេកអ៊ាវ *ហៅ* ឌុច: | លោក Brianne McGONIGLE |
| | លោកស្រី Annie DELAHAIE |
| **មេធាវីជនជាប់ចោទ/ដើមបណ្ដឹងសាទុក្ខ:** | លោកស្រី Elizabeth RABESANDRATANA |
| លោក ការ សាវុត្ថ | លោក Karim KHAN |
| លោក កង ឫទ្ធារី | លោកស្រី Fabienne TRUSSES-NAPROUS |

## សេចក្ដីសង្ខេប

១. សហព្រះរាជអាជ្ញា មិនយល់ទាស់នឹងសំណើរបស់ កាំង ហ្គេកអ៊ាវ *ហៅ* ឌុច ("ដើមបណ្ដឹងសាទុក្ខ") សុំបន្ថែមពេលវេលា ៣០ ថ្ងៃ ដើម្បីដាក់សារណាបណ្ដឹងសាទុក្ខរបស់គាត់ ប្រឆាំងទៅនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ("សំណើ")[1] ទេ ។ ទោះជាយ៉ាងនេះក្ដី ការបន្ថែមពេលវេលានេះ គួរតែត្រូវបានអនុញ្ញាតដោយឈរលើមូលដ្ឋានដែលថា ដើមបណ្ដឹងសាទុក្ខបានបញ្ចូលមេធាវីជាតិបន្ថែមមួយរូបទៀត ដែលនេះអាចជាសេចក្ដីត្រូវការនូវពេលវេលាបន្ថែមសមហេតុផលក្នុងការត្រៀមបណ្ដឹងសាទុក្ខ។ អំណះអំណាងទាំងអស់ផ្សេងទៀតដែលមាននៅក្នុងសំណើ ដូចជាការលើកឡើងអំពីភាពស្មុគស្មាញ ឬវិសមភាពនៃសិទ្ធិអំណាច រវាងដើមបណ្ដឹងសាទុក្ខ និងសហព្រះរាជអាជ្ញា គឺជាកង្វះនូវអង្គសេចក្ដី និងគួរតែត្រូវបានច្រានចោល ។

## ការចាត់តាំងមេធាវីថ្មី គឺជានត្ថិករណ៍យកជាការបានសម្រាប់ការបន្ថែមពេលវេលា

២. នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១០ នៅពីរ-បីថ្ងៃ មុនការប្រកាសសាលក្រម ដើមបណ្ដឹងសាទុក្ខបានជ្រើសរើសដោយស្ម័គ្រចិត្តដើម្បីបញ្ចប់សេវារបស់លោក François Roux ជាមេធាវីការពារក្ដីអន្តរជាតិរបស់គាត់ ដែលមេធាវីរូបនេះបានបំរើការងារក្នុងសមត្ថភាពនេះ អស់រយៈពេលប្រហែល ៣ឆ្នាំ[2]។ នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ អង្គជំនុំជម្រះសាលាដំបូង បានចេញសាលក្រមរបស់ខ្លួនដោយកាត់សេចក្ដីឱ្យដើមបណ្ដឹងសាទុក្ខជាប់ទោសចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចបានថែង និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ហើយបានដាក់ទោសគាត់ ៣៥ឆ្នាំ[3]។ បន្ទាប់ពីនោះមក នៅថ្ងៃទី៦ ខែសីហា ឆ្នាំ២០១០ ជំនួសឱ្យការជ្រើសយកមេធាវីការពារក្ដីអន្តរជាតិម្នាក់ផ្សេង ដូចដែលបានអនុញ្ញាតតាមវិធានផ្ទៃក្នុង ("វិធាន")[4] ដើមបណ្ដឹងសាទុក្ខបានជ្រើសយកសំណើសុំសេវាពីលោក កង ឫទ្ធារី ជាមេធាវីជាតិទីពីរ បន្ថែមលើ លោក ការ សាវុត្ថ

[1] សំណើរបស់មេធាវីការពារក្ដី កាំង ហ្គេកអ៊ាវ ហៅ ឌុច សុំបន្ថែមពេលវេលាកំណត់សម្រាប់ដាក់សារណាបណ្ដឹងសាទុក្ខ ជំទាស់ទៅនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ចេញថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០, ដែលបានដាក់នៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១០ និងបានជូនដំណឹងដល់គូភាគីនៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១០, សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អវតក/អជតក ("សំណើ"), កថាខ័ណ្ឌទី៣.៣ ។

[2] សេចក្ដីប្រកាសព័ត៌មានរបស់អង្គភាពគាំពារការការពារក្ដីនៃ អ.វ.ត.ក, ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១០ ។

[3] សាលក្រម, សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អវតក/អជសដ, ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០, ឯកសារលេខ: E188 ។

[4] វិធានផ្ទៃក្នុង, ច្បាប់វិសោធនកម្មលើកទី៥, ចុះថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១០ ("វិធាន"), វិធាន២២.១ ។

ដែលគាត់បានបំរើការងារក្នុងសមត្ថភាពនេះ តាំងពីដើមបណ្តឹងសាទុក្ខចូលបង្ហាញខ្លួនលើកដំបូងនៅចំពោះមុខ អ.វ.ត.ក[5]។

៣. នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១០ ដើមបណ្តឹងសាទុក្ខ បានដាក់សេចក្តីជូនដំណឹងមួយអំពីបណ្តឹងសាទុក្ខជំទាស់នឹងសាលក្រម (“សេចក្តីជូនដំណឹងរបស់មេធាវី”) ដោយបានលើកឡើងអំពីការភាន់ច្រឡំផ្នែកច្បាប់ដ៏តូចចង្អៀតចំនួនពីរ សំខាន់បំផុតគឺការអះអាងថា អង្គជំនុំជម្រះសាលាដំបូង មានកង្វះខាតផ្នែកយុត្តាធិការបុគ្គលក្នុងការវិនិច្ឆ័យទោសរូបគាត់[6]។ គ្មានទឡ្ហីករណ៍ណាផ្សេងឡើយនៃបណ្តឹងសាទុក្ខត្រូវបានលើកឡើងទេ។ ដើមបណ្តឹងសាទុក្ខ មានពេលរហូតដល់ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១០ ដើម្បីដាក់បណ្តឹងសាទុក្ខរបស់ខ្លួន[7] ។ មាត្រា ១៤.៣.ខ នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (“ICCPR”) ដែលចងកាតព្វកិច្ចចំពោះតុលាការនេះ ផ្តល់ឲ្យចុងចោទ ដូចជាដើមបណ្តឹងសាទុក្ខនេះនូវសិទ្ធិទទួលបានពេលវេលា និងផាសុបករណ៍គ្រប់គ្រាន់ក្នុងការត្រៀមរៀបចំការការពារខ្លួនគាត់ និងដើម្បីប្រាស្រ័យទាក់ទងជាមួយមេធាវីតាមការជ្រើសរើសដោយផ្ទាល់ខ្លួន[8] ។

៤. នៅក្នុងករណីនេះ ដើមបណ្តឹងសាទុក្ខបានជ្រើសរើសដោយស្ម័គ្រចិត្តក្នុងការ៖ ទី១) បណ្តេញមេធាវីការពារក្តីអន្តរជាតិនៅមុនសាលក្រមបន្តិច ទោះបីជាដំណើរការនីតិវិធីជំនុំជម្រះក្តីបានបញ្ចប់នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩ ក៏ដោយ ទី២) មិនទទួលយកមេធាវីការពារក្តីអន្តរជាតិណាម្នាក់មកវិញទេ ទោះបីជាគាត់ត្រូវមានសិទ្ធិក្នុងការមានមេធាវីការពារក្តីអន្តរជាតិម្នាក់ក៏ដោយ ទី៣) ទើបតែទទួលយកមេធាវីការពារក្តីជាតិបន្ថែមម្នាក់ទៀត នៅក្រោយពេលមានសាលក្រមតែប៉ុណ្ណោះ និងទី៤) ទទួលយកមេធាវីការពារក្តីជាតិបន្ថែមម្នាក់នោះ ទោះបីជាវិធាន ២២.១ អនុញ្ញាតឲ្យមានមេធាវីការពារក្តីជាតិតែម្នាក់ក៏ដោយ។ លើកលែងតែការដកហូតលោក François Roux និងការតែងតាំងលោក កង ឫទ្ធារី នោះ សមាសភាពនៃក្រុមមេធាវីការពារក្តីគឺនៅតែដដែល

---

[5] ការកត់សំគាល់អំពីការតែងតាំងសហមេធាវីការពារក្តី, សំណុំរឿងលេខៈ ០០១/១៨-០៧-២០០៧-អវតក/អជសដ, ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០១០, ឯកសារលេខៈ E189 ។

[6] សេចក្តីជូនដំណឹងរបស់សហមេធាវីការពារក្តីជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច អំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ របស់អង្គជំនុំជម្រះសាលាដំបូង, សំណុំរឿងលេខៈ ០០១/១៨-០៧-២០០៧-អវតក/អជសដ, ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១០, ឯកសារលេខៈ E188/8 ។

[7] វិធាន, វិធាន១០៧.៤ (ផ្តល់ឲ្យភាគីប្តឹងនូវរយៈពេល៦០ថ្ងៃ ដើម្បីដាក់បណ្តឹងសាទុក្ខរបស់ខ្លួន គិតចាប់ពីថ្ងៃដាក់សេចក្តីជូនដំណឹងនៃបណ្តឹងសាទុក្ខ) ។

[8] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ, ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣, មាត្រា១២.២ ។

ពុំមាន ការផ្លាស់ប្តូរអ្វីទេ។ លោក ការ សាវុត្ថ បានបំពេញការងារសម្រាប់ដើមបណ្តឹងសាទុក្ខ ជាប់ជាប្រចាំ អស់រយៈពេលជាច្រើនឆ្នាំ តាំងពីមុនការចូលបង្ហាញខ្លួនដំបូងនៅ អវតក នៅពេលដែលដើមបណ្តឹងសាទុក្ខត្រូវបានឃុំខ្លួនដោយអាជ្ញាធរយោធាកម្ពុជា។

៥. លោក ចាន់ រ៉ាវុធ ជាអ្នកជំនាញច្បាប់កម្ពុជាដែលមានបទពិសោធន៍ និងមានគុណវុឌ្ឍិយ៉ាងគ្រប់គ្រាន់ បានបន្តធ្វើជាអ្នកគ្រប់គ្រងសំណុំរឿង។ ដើមបណ្តឹងសាទុក្ខបានរក្សាទុកនូវសេវានានារបស់ទីប្រឹក្សាច្បាប់ និងនិរន្តរភាពនៃអ្នកបកប្រែដែលមានគុណវុឌ្ឍិយ៉ាងខ្ពស់ និងពហុភាសាដែលត្រូវបានសម្របសម្រួលដោយអង្គភាពគាំពារមេធាវីការពារក្តី ("DSS")[9]។ នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១០ បណ្តាញសារព័ត៌មានអន្តរជាតិបានរាយការណ៍ថា ដើមបណ្តឹងសាទុក្ខក៏ធ្លាប់បានរក្សាទុកនូវសេវានានារបស់លោក Nick Kaufman ជាមេធាវីព្រហ្មទណ្ឌអន្តរជាតិដែលបានទទួលការអប់រំ និងបណ្តុះបណ្តាលនៅចក្រភពអង់គ្លេស ដែលមានបទពិសោធន៍យ៉ាងទូលំទូលាយនៅក្នុងការដឹកនាំធ្វើសំណុំរឿងផ្សេងៗ នៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិអចិន្ត្រៃយ៍ ("ICC") តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ("ICTY") និងនៅតុលាការក្រុង Jerusalem[10]។ បន្ថែមលើនេះ ទៅតាមវិធាន ១១.២.ញ ដើមបណ្តឹងសាទុក្ខមានជំនួយពីសំណាក់ DSS ដែលត្រូវបានអនុញ្ញាតឲ្យផ្តល់ជំនួយ និងការគាំទ្រផ្នែកច្បាប់ជាមូលដ្ឋាន ដែលរាប់បញ្ចូលទាំងការស្រាវជ្រាវខាងវិស័យច្បាប់ និងឯកសារច្បាប់នានា ព្រមទាំងទាញយកនូវឯកសារទាំងនោះ សម្រាប់មេធាវីការពារក្តីដាក់បង្ហាញនៅចំពោះមុខ អវតក ថែមទៀតផង ។

៦. ទោះបីជាមានភាពគ្រប់គ្រាន់នៃការគាំទ្រខាងវិស័យច្បាប់ ចំពោះដើមបណ្តឹងឧទ្ធរណ៍យ៉ាងណាក៏ដោយក៏ សហព្រះរាជអាជ្ញាយល់ឃើញថាវាជាបមាណីយនៃការកាត់សេចក្តីដ៏ត្រឹមត្រូវជាអន្តរជាតិមួយ ដែលត្រូវអនុញ្ញាតឲ្យមានមេធាវីការពារក្តីតែងតាំងថ្មីមួយ ដែលសមស្របទៅតាមពេលវេលាដើម្បីធ្វើការត្រៀមរៀបចំសំណុំរឿង ក្នុងគោលបំណងដើម្បីជួយដល់កូនក្តីរបស់ខ្លួនឲ្យបានត្រឹមត្រូវ[11] ។ ជាលទ្ធផល សំណើនេះមិនត្រូវបានជំទាស់ទេ។

## ការចោទប្រកាន់ពីភាពស្មុគ្រស្មាញ និងទំហំនៃករណីរឿង
## គឺមិនមែនជាហេតុផលសម្រាប់ឲ្យធ្វើការពន្យារពេលនោះទេ

---

[9] សំណើ, កថាខណ្ឌទី ៣.iii (ដែលបានលើកឡើងពីការបន្តទៀតនៃទីប្រឹក្សាច្បាប់) ។

[10] ទីប្រឹក្សាការពារក្តីថ្មីរបស់ ឌុច, កាសែត Phnom Penh Post, ថ្ងៃទី១៧ សីហា ២០១០, អាចរកបាននៅតាមវិបសាយ៖ "http://www.phnompenhpost.com/index.php/component/option,com_myblog/Itemid,44/show,new-defence-consultant-for-duch.html./"

[11] *រដ្ឋអាជ្ញា ទល់នឹង Karadzic,* សេចក្តីសម្រេចលើញត្តិស្នើសុំពន្យារពេលដាក់ចម្លើយតប, IT-95-5/18-T, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY, ថ្ងៃទី១២ វិច្ឆិកា ២០០៩, កថាខណ្ឌទី ១-២ ។

៧. ដើមបណ្តឹងសាទុក្ខបានចោទប្រកាន់ថា "ទំហំ និងភាពស្មុគស្មាញ នៃករណីរឿង [និង] ភាពថ្មីប្លែកនៃបញ្ហាដែលបានលើកឡើង" គួរតែជាមូលហេតុសម្រាប់ការពន្យារពេលបន្ថែម[12]។ ជាការគាំទ្រ គាត់បានលើកសំអាងអំពីអង្គហេតុដែលថា (១) សវនាការជំនុំជម្រះក្តីបានធ្វើឡើងអស់រយៈពេលជិតមួយឆ្នាំ ដោយមានការដាក់ឯកសារជាច្រើនទំព័រនៅក្នុងករណីរឿង (២) សាលក្រមមានចំនួនជាងបួនរយទំព័រជាភាសាខ្មែរ ហើយ ៣) ការពិភាក្សាលំអិត និងការស្រាវជ្រាវបន្ថែមដ៏មានសារៈសំខាន់គឺជាការចាំបាច់សម្រាប់មេធាវីការពារក្តី ដើម្បីរៀបចំការឆ្លើយតបឲ្យបានគ្រប់គ្រាន់ដោយភាពប៉ិនប្រសប់ទៅនឹងបរិមាណដ៏ច្រើននៃឯកសារនេះ[13]។

៨. សហព្រះរាជអាជ្ញា សូមស្នើដល់អង្គជំនុំជម្រះតុលាការកំពូលឲ្យបដិសេធចោលនូវមូលហេតុទាំងនេះ។ បណ្តឹងសាទុក្ខណាមួយគឺមិនមែនជាការជំនុំជម្រះក្តី *ឡើងវិញសាជាថ្មី* នោះទេ[14]។ គឺបណ្តឹងសាទុក្ខត្រូវបានកម្រិតកំណត់ត្រឹមតែការភាន់ច្រឡំផ្នែកអង្គហេតុ និងអង្គច្បាប់ដែលត្រូវបានបង្ហាញអត្តសញ្ញាណដោយដើមបណ្តឹងសាទុក្ខនៅក្នុងបណ្តឹងសាទុក្ខរបស់ខ្លួន[15]។ ដើមបណ្តឹងសាទុក្ខ បានលើកឡើងអំពីតែ "ការភាន់ច្រឡំផ្នែកអង្គច្បាប់" ដ៏សំខាន់មួយគត់ប៉ុណ្ណោះ[16] ដែលថា អង្គជំនុំជម្រះសាលាដំបូងមិនមានយុត្តាធិការបុគ្គលទៅលើរូបគាត់ទេ ដែលហេតុដូចនេះ គាត់គួរតែត្រូវបានលើកលែងការចោទប្រកាន់[17]។ នេះគឺវាមិនមែនជាបញ្ហាថ្មីនោះទេ តាមពិតទៅមេធាវីការពារក្តីជាតិរបស់ដើមបណ្តឹងសាទុក្ខបានលើកឡើងអំពីបញ្ហានេះ នៅក្នុងអំណះអំណាងបិទការពិភាក្សាដេញដោលរបស់ខ្លួន ទោះបីសេចក្តីសម្រេចមួយរបស់សហចៅក្រមស៊ើបអង្កេត មិនដែលត្រូវបានលើកឡើងជាការតវ៉ាជំទាស់ទាក់ទងនឹងយុត្តាធិការ នៅក្នុងអឡុងពេលសវនាការបឋមអនុលោមតាមវិធាន៨៩នៃវិធានផ្ទៃក្នុងនោះក៏ដោយ[18]។ លោកសាស្ត្រាចារ្យ Raoul Jennar ជាអ្នកប្រវត្តិវិទូដែលបានផ្តល់សក្ខីកម្ម នៅក្នុងពេលសវនាការតាងនាមឲ្យដើមបណ្តឹងសាទុក្ខបានប្រកាន់យកនូវ

---

[12] សំណើសុំ, កថាខណ្ឌទី២។

[13] សំណើសុំ, កថាខណ្ឌទី៣.១។

[14] *ករណីរឿងក្តីរបស់អ្នកអាជ្ញា* ទល់នឹង *Galić, សាលក្រម,* សំណុំរឿងលេខ IT-98-29-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃ តុលាការ ICTY, ចុះថ្ងៃទី៣០ វិច្ឆិកា ២០០៦, កថាខណ្ឌទី ៣៨៣។

[15] វិធាន១០៤.១ និង១១០ នៃវិធានផ្ទៃក្នុង។

[16] សំណើសុំ, កថាខណ្ឌទី៦។

[17] សំណើសុំ, កថាខណ្ឌទី៧-១០។

[18] សាលក្រម, កថាខណ្ឌទី១៥។

ជំហរដូចគ្នានៅក្នុងរបាយការណ៍របស់ខ្លួនដែលបានដាក់ជូនទៅសហចៅក្រមស៊ើបអង្កេតយ៉ាងឆាប់បំផុតត្រឹមថ្ងៃទី៩ ខែឧសភា ឆ្នាំ២០០៨ យ៉ាងយូរមុនពេលចាប់ផ្តើមបើកសវនាការ[19]។

៩. សហព្រះរាជអាជ្ញា សូមជូនសេចក្តីសន្និដ្ឋានថា ទំហំនៃសាលក្រមអាចប្រៀបធៀបបានជាមួយនឹងសាលក្រមណាមួយផ្សេងទៀត ដែលត្រូវបានចេញដោយតុលាការព្រហ្មទណ្ឌណាមួយស្រដៀងគ្នានេះ និងហេតុផលដែលបានលើកឡើងនៅក្នុងសេចក្តីជូនដំណឹងរបស់មេធាវីការពារក្តី គឺមានលក្ខណៈតូចចង្អៀត និងមិនទាមទារពេលវេលាបន្ថែមដូចដែលដើមបណ្តឹងសាទុក្ខបានតវ៉ាថា តម្រូវចាំបាច់សម្រាប់បណ្តឹងសាទុក្ខ។ ជាងនេះទៅទៀត មានសមាជិកនៃក្រុមមេធាវីការពារក្តីមួយចំនួនដូចជាលោក ការ សាវុត្ថ និងលោក ចាន់ រ៉ាវុធ ដែលធ្លាប់ជាប់ពាក់ព័ន្ធនៅក្នុងរឿងក្តីនេះចាប់តាំងពីពេលចូលបង្ហាញខ្លួនលើកដំបូងជាង៣ឆ្នាំមកហើយ និងដែលមានភាពជិតស្និទ្ធយ៉ាងល្អជាមួយនឹងរាល់សេចក្តីថ្លែងសំអាង និងភស្តុតាង។ អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញា សូមជូនសេចក្តីសន្និដ្ឋានថា ក្រុមមេធាវីការពារក្តីនានាគួរតែពឹងផ្អែកលើកិច្ចសហប្រតិបត្តិការគ្នាទៅវិញទៅមករវាងសមាជិករបស់ខ្លួន ក្នុងការដំណើរការរឿងក្តីនានានៅចំពោះមុខតុលាការកូនកាត់នេះក្នុងលក្ខណៈដូចគ្នា ដូចដែលបានគ្រោងទុកជាមុនដោយអង្គបុរេជំនុំជម្រះ នៅក្នុងបញ្ហានានាទាក់ទិននឹងការបកប្រែឯកសារ[20]។

១០. ជាបន្ថែមពីលើនេះ "ភាពស្មុគ្រស្មាញនៃករណីរឿង និងភាពល្អិតល្អន់នៃឯកសារ [...] គឺជាកត្តាដែលនៅក្នុងគ្រប់រាល់ករណីរឿងទាំងអស់"[21] ហើយដើមបណ្តឹងសាទុក្ខមិនបានបញ្ជាក់ឱ្យដឹងអំពីកាលៈទេសៈពិសេសណាមួយ ដែលគួរឱ្យពន្យារពេលបន្ថែមមួយខែទៀត ពីលើរយៈពេលអតិបរិមាចំនួនបីខែដែលច្បាប់កំណត់សម្រាប់ការដាក់បណ្តឹងសាទុក្ខឡើយ។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាសូមជូនសេចក្តីសន្និដ្ឋានថា វិសាលភាពដ៏តូចចង្អៀតនៃសេចក្តីជូនដំណឹងរបស់មេធាវីការពារក្តី

[19] របាយការណ៍ដែលធ្វើឡើងដោយទីប្រឹក្សា Raoul M. Jennar, PhD ក្នុងការសិក្សាស្រាវជ្រាវអំពីខ្មែរ និងវិភាគនយោបាយ, សំណុំរឿងលេខ ០០១១/១៨-០៧-២០០៧-អវតក-កសចស, ចុះថ្ងៃទី៩ឧសភា២០០៨, D108/4, ទំព័រ១០-១៣ ។

[20] សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផនប្រឆាំងនឹងដីកាសម្រេចស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគី ក្នុងការបកប្រែ, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ១១), ចុះថ្ងៃទី២០ កុម្ភៈ ២០០៩, A190/1/20, កថាខណ្ឌទី៤៦,៥០។

[21] *ករណីរឿងក្តីរបស់រដ្ឋអាជ្ញា* ទល់នឹង *Blagojević,* ដីកាសម្រេចលើញត្តិស្នើសុំរបស់ *Vladoje Blagojević* ពន្យារបន្ថែមពេលវេលាដើម្បីដាក់សេចក្តីជូនដំណឹងស្តីពីការដាក់សារណានៃបណ្តឹងឧទ្ធរណ៍របស់ខ្លួន, សំណុំរឿងលេខ IT-02-60-A, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY, ចុះថ្ងៃទី១៤ មេសា ២០០៥, ទំព័រ ៣ (ទោះបីជាតុលាការ ICTY បានអនុញ្ញាតឱ្យពន្យាពេលបន្ថែមក្តី ក៏តុលាការនេះមិនអនុញ្ញាតឱ្យនូវរយៈពេលដែលមិនធម្មតាដូចដែលបានស្នើសុំនោះដែរ)។

គឺមិនទាមទារឲ្យពន្យារពេលបន្ថែមសម្រាប់ការត្រៀមរៀបចំបណ្ដឹងសាទុក្ខនោះទេ។ ដូចនេះ ហេតុផលសម្រាប់ការពន្យារពេលបន្ថែម គួរតែត្រូវបានបដិសេធចោល។

## តាមការចោទប្រកាន់ ថាមិនមានវិសមភាពខាងសិទ្ធិអំណាច

១១. ដើមបណ្ដឹងឧទ្ធរណ៍អះអាងថា ដោយសារថាការិយាល័យសហព្រះរាជអាជ្ញា ("កសព") ប្រតិបត្តិការជាមួយ "មន្ត្រីផ្នែកច្បាប់ ៣-៤ ដង ដែលខ្លួនបានប្រើ [ច្រើន]" ជាងក្រុមការពារក្ដី ហេតុដូច្នេះ មានការចោទប្រកាន់ខ្លះ ហើយការពន្យារពេលគួរតែត្រូវបានផ្ដល់ឲ្យ[22]។ សហព្រះរាជអាជ្ញាស្នើសុំថា តុលាការកំពូលបដិសេធចោលសេចក្ដីអះអាងនេះ។ បទដ្ឋាននៃការកាត់ក្ដីប្រកបដោយយុត្តិធម៌ មិនតម្រូវឲ្យភាគីនិមួយៗ ត្រូវតែទទួលបានដោយច្បាស់លាស់នូវសិទ្ធិ និងភាពងាយស្រួលដូចគ្នាទេ។ ជាងនេះទៅវិញ វាផ្ដល់អាណត្តិថាភាគីនិមួយៗ ត្រូវទទួលបានឱកាសដ៏សមស្របមួយ ដើម្បីដាក់បង្ហាញករណីរបស់ខ្លួន ក្នុងលក្ខណៈដែលមិនដាក់រូបគេឲ្យស្ថិតក្នុងស្ថានភាពចាញ់ប្រៀបដ៏ធ្ងន់ធ្ងរណាមួយ[23]។ តាមពិតទៅ ការណ៍នេះគឺជាករណីនៅទីនេះ។ ទោះបីជាបណ្ដឹងឧទ្ធរណ៍របស់ក្រុមការពារក្ដីរបស់សហមេធាវីជាតិ២នាក់ ក៏អ្នកចាត់ចែងសំណុំរឿងម្នាក់ ទីប្រឹក្សាផ្នែកច្បាប់អន្តរជាតិម្នាក់លោក Nic Kaufman និងកម្មសិក្សាការីមួយចំនួន បានរួមជាមួយ ផកក ធ្វើការផ្ដាច់មុខតែក្នុងករណីរបស់ដើមបណ្ដឹងឧទ្ធរណ៍ ទៅកាន់តុលាការកំពូលដែរ កសព គឺជាការិយាល័យឯករាជ្យមួយរបស់តុលាការនេះ ដែលមានការទទួលខុសត្រូវលើកិច្ចការផ្នែកច្បាប់ រដ្ឋបាល និងនយោបាយសាធារណៈផ្សេងៗពីគ្នា។

១២. សហព្រះរាជអាជ្ញា ឬប្រតិភូរបស់អស់លោក-លោកស្រី ជាអ្នកទទួលខុសត្រូវក្នុងការដឹកនាំធ្វើការងារនៃករណីនានាដែលកំពុងប្រព្រឹត្តទៅ ឬដែលនឹងមានមកទៀត ចំពោះចុងចោទនានា បច្ចុប្បន្ន

[22] សំណើរ, កថាខ័ណ្ឌ ៣(iii)។

[23] *រដ្ឋអាជ្ញា vs Tadic,* សេចក្ដីសម្រេចអង្គជំនុំជម្រះសាលាឧទ្ធរណ៍ IT-94-I-A, ICTY ថ្ងៃទី១៥ កក្កដា ១៩៩៩ កថាខណ្ឌ៤៨(ដកស្រង់គណៈកម្មការសិទ្ធិមនុស្សអឺរ៉ុបក្នុងករណី Kaufman vs Belgium ដែលនិយាយថា សិទ្ធិអំណាចស្មើគ្នា មានន័យថា ភាគីនិមួយគួរតែមានឱកាសសមរម្យដើម្បីការពារផលប្រយោជន៍របស់ខ្លួន "ក្រោមលក្ខខណ្ឌដោយមិនដាក់គាត់ស្ថិតនៅក្នុងស្ថានភាពបាត់បង់ប្រយោជន៍ច្រើនហួសហេតុ ទាក់ទិនទៅនឹងការជំទាស់របស់គាត់")។

និងដែលនឹងស្នើឡើងរបស់តុលាការនេះ ចំពោះមុខសហចៅក្រមស៊ើបអង្កេត អង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង និងតុលាការកំពូល។ អង្គរបស់តុលាការនេះមានការទទួលខុសផងដែរក្នុងការស៊ើបអង្កេតបឋម និងទទួល និងវិភាគពាក្យបណ្ដឹងពីអ្នកដាក់ពាក្យបណ្ដឹងរាប់ពាន់នាក់។ ក្រៅពីនេះទៀត សហព្រះរាជអាជ្ញាមានការទទួលខុសត្រូវផ្នែករដ្ឋបាលដែលជាផ្នែកមួយមិនអាចដាច់ចេញពីគ្នាបានរបស់អង្គតុលាការនេះ។

១៣. និយាយដោយសង្ខេប ក្រុមការពារក្ដីនៃដើមបណ្ដឹងឧទ្ធរណ៍ ទទួលបានភាពងាយស្រួលនានាទាំងអស់ ហើយពុំមានភាពចាញ់ប្រៀបណាមួយទេ ចំពោះសហព្រះរាជអាជ្ញាក្នុងការរៀបចំករណីនេះ។ ហេតុដូច្នេះ ពុំមានវិសមភាពខាងសិទ្ធិអំណាច ទោះបីចំពោះមុខ ឬជាក់ស្ដែងណាមួយទេ ហើយទឡ្ហីករណ៍នេះត្រូវបដិសេធចោលភ្លាមៗតែម្ដង។

## សេចក្ដីសន្និដ្ឋាន

១៤. សហព្រះរាជអាជ្ញាស្នើសុំថា អង្គជំនុំជម្រះតុលាការកំពូលផ្ដល់ដល់ការដាក់ពាក្យបណ្ដឹងនូវការពន្យារពេលដោយឈរលើមូលដ្ឋានដែលថា ដើមបណ្ដឹងឧទ្ធរណ៍ទើបបានទទួលយកមេធាវីជាតិថ្មីម្នាក់ តែសូមឲ្យបដិសេធចោលនូវលេសផ្សេងទៀតទាំងអស់លើកឡើងដោយដើមបណ្ដឹងឧទ្ធរណ៍ ដើម្បីគាំទ្រដល់ពាក្យបណ្ដឹងរបស់ខ្លួន៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | | |
| | **លោក Andrew CAYLEY**<br>សហព្រះរាជអាជ្ញា | | |